# ផលិតផលការពារជម្រាបទឹក

ការជ្រាបទឹកជាការរំខានអារម្មណ៍ ប៉ះពាល់សោភ័ណភាព គេហដ្ឋាន និងអនាម័យ។

ការសង់គេហដ្ឋានមួយ ជាការចំណាយប្រាក់កាសជាច្រើន និងមោទនភាព របស់គ្រួសារមួយៗ

ជាទូទៅយើងបានចំណាយលុយទិញរបស់ថ្លៃៗបានប៉ុន្តែយើងបែរទៅជាភ្លេចរបស់ការពារដូចជាផលិតផលការពារជម្រាបទឹកជាដើម។

ការពិតផលិតផលការពារជម្រាបទឹក មានតម្លៃមិនស្មើនឹងពាក់កណ្តាលនូវតម្លៃផ្ទះមួយ ដែលវាអាចការពារ ការជ្រាបទឹកបានរាប់ឆ្នាំ។







CAM-PAINT
ថ្នាំពណ៌ជាតិ

## ម្សៅបៀក និង ថ្នាំពណ៌ ដែលល្អគ្មានគូប្រៀប




ផ្លូវលេខ 217 (ផ្លូវជើងឯក) ភូមិព្រែកស្វាយ សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ
015 888 010 / 015 999 453 / 097 688 5657
www.campaint-ccsc.com.kh
info@campaint-ccsc.com.kh
Cambodian Chemical Supply
Cam-paint

សម្រាប់ផ្នែកប្រឹក្សាយោបល់៖ ☎ 016 59 59 09 / 015 888 003




# ម្សៅបៀក

## តើយើងប្រើម្សៅបៀកដើម្បីអ្វី?

- បិទភ្ជិតស្នាមប្រេះ
- បំពេញរន្ធតូចៗ និង ធ្វើអោយផ្ទៃរាបស្មើ
- ការពារជញ្ជាំងទល់នឹងសំណើក
- ចំណេញថ្នាំទ្រនាប់ និងស្ប៉ាត្រូ ( ថ្នាំសម្រេច )

## តើយើងប្រើម្សៅបៀកយ៉ាងដូចម្តេច?

- ទុកជញ្ជាំងបុកស៊ីម៉ងត៍ អោយស្ងួតយ៉ាងតិច ៧ថ្ងៃ
- បើជញ្ជាំងស្ងួតពេកត្រូវស្រោចទឹកសិន មុនពេលបៀក
- សម្អាតផ្ទៃជញ្ជាំងអោយបានល្អ
- ពេលលាយទឹក(ទឹកស្អាត) ត្រូវកូរអោយបានសព្វជាល្បាយស្មើសាច់ បើយកល្អកូរដោយម៉ូទ័រ
- ទុកប្រមាណជា១០នាទីសិន មុនយកទៅបៀក
- បៀក និងសីបង្ហាប់ដោយប្រើស្លាបព្រាដែកក្នុងកម្រាស់ ២-៣ មម
- ទុកម្សៅបៀកអោយស្ងួតយ៉ាងតិច ៣ថ្ងៃ មុនលាបថ្នាំ។

**បញ្ជាក់:**

បើសីមិនហាប់ល្អទេ សូមស្រោចទឹកអោយបាន១-២ ដង ដើម្បីអោយសាច់ណែនរឹង ជាប់ជញ្ជាំងបានល្អសិនទើបសាងរបក ចាត់ក្រោយរញ្ជួថ្នាំទ្រនាប់ និងស្ប៉ាត្រូ។




# ថ្នាំទ្រនាប់

## ហេតុដូចម្តេចបានជាយើងចាំបាច់ប្រើថ្នាំទ្រនាប់?

- ធ្វើអោយផ្ទៃរឹងមាំ
- បន្ថែមភាពជាប់ស្អិត
- ការពារជាតិក្បុងនិងជាតិប្រៃដែលបង្កអោយមានក្រឡាខ្នីង
- ធ្វើអោយថ្នាំជាប់បានយូរ
- ចំណេញថ្នាំ ស្ប៉ាត្រូ ( ថ្នាំសម្រេច )

## ប្រភេទថ្នាំទ្រនាប់

- ថ្នាំទ្រនាប់លាយទឹក (សម្រាប់ជញ្ជាំងចាស់និងថ្មី)
- ថ្នាំទ្រនាប់លាយប្រេង (សម្រាប់ផ្ទៃឈើ និងដែក)

## តើត្រូវប្រើថ្នាំទ្រនាប់យ៉ាងដូចម្តេច?

- លាយទឹក ប្រេងលាយ អោយរាវល្មម
- រុញលើផ្ទៃស្អាត និងស្ងួតល្អ (ថ្នាំទ្រនាប់លាយប្រេង)
- រុញតែមួយទឹកគត់ ហើយទុកចោលប្រហែល១ម៉ោង មុនរុញថ្នាំ

**បញ្ជាក់:**

ការទុកថ្នាំទ្រនាប់អោយស្ងួតយូរពេកនាំអោយពិបាករុញថ្នាំពីលើ




# ថ្នាំពណ៌

ថ្នាំពណ៌ដូចជាគ្រឿងសម្អាងដែលធ្វើអោយសម្រស់ស្រស់ស្អាតអញ្ចឹងដែរ។ គេហដ្ឋានដែលលាបថ្នាំពណ៌មិនបានស្អាតប្រៀបដូចជាការតែងខ្លួនដែលមានតែសំលៀកបំពាក់អលង្ការតែខ្វះគ្រឿងសម្អាងដែលយើងមិនអាចខ្វះបាន។ ចាំ-ផែន មានថ្នាំពណ៌ដែលអាចបំពេញតម្រូវការបានទាំងអស់ ទាំងបែប ភ្លឺខ្លាំង ភ្លឺល្មម និង បែបធម្មតា។

## គួរលាបថ្នាំពណ៌យ៉ាងដូចម្តេចដើម្បីអោយជាប់ ហើយស្អាត?

- ត្រូវលាបលើផ្ទៃដែលស្អាត ស្ងួតល្អ និងរឹងមាំ
- ទឹកទី១ លាយអោយរាវបន្តិច ដើម្បីអោយទឹកថ្នាំជ្រាបចូលផ្ទៃជញ្ជាំង ចាំជាប់បានល្អ។
- ទឹកទី២ លាយថ្នាំអោយល្មម (ជាទឹកបញ្ចើយក៏បាន)
- ទឹកទី៣ (បើចាំបាច់) លាយអោយរាវបន្តិចវិញដើម្បីសាច់ថ្នាំរាបល្អ។

**បញ្ជាក់:**

ព្រះរាជាណាចក្រកម្ពុជាយើង ស្ថិតក្នុងតំបន់ត្រូពិច (tropic) ដែលមានអាកាសធាតុក្តៅហើយសើម។ដូច្នេះការរើសពណ៌ដែលអាចទប់នឹងអាកាសធាតុបានយូរគឺជាការចាំបាច់ណាស់។ អ្នកបច្ចេកទេសយើងខ្ញុំអាចផ្តល់យោបល់បាន។

